**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ដំណឹងជ្រើសរើសបុគ្គលិក

ចាប់តាំងពីចុងឆ្នាំ២០០៤ មក រាជរដ្ឋាភិបាលកម្ពុជាដោយមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានចាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាជំហានៗ មានរយៈពេលវែងដែលមានគោលបំណងកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាឆ្ពោះទៅរកស្តង់ដារអន្តរជាតិ។ ការអនុវត្តកម្មវិធីនេះបានទទួលជោគជ័យជាបន្តបន្ទាប់ ហើយកំពុងបន្តអនុវត្តជំហានបន្ទាប់ទៀត។ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានមុខងារ និងភារកិច្ចសម្របសម្រួលការរៀបចំ និងការអនុវត្តការងារគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសម្របសម្រួលការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ដោយមានចក្ខុវិស័យច្បាស់លាស់ និងក្នុងនាមជាសេនាធិការប្រកបដោយគុណភាព ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព អគ្គលេខាធិការដ្ឋានត្រូវការចាំបាច់នូវមន្ត្រីបម្រើការងារមួយចំនួនដែលមានសមត្ថភាព មានជំនាញ និងមានបទពិសោធន៍សមស្របតាមការងារនីមួយៗ។

ក្នុងន័យនេះ អគ្គលេខាធិការដ្ឋានសូមប្រកាសជ្រើសរើសមន្ត្រីបច្ចេកទេសព័ត៌មានវិទ្យា (ICT) ចំនួន១០រូបសម្រាប់បម្រើការងារពេញម៉ោងនៅលេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចខាងក្រោម÷

- Web Developer / Programmer (០៣តំណែង)
- IT Security Analyst/ Specialist (០២តំណែង)
- System Administrators (០២តំណែង)
- IT Support Officer (០២តំណែង)
- Cable Cabling (០១តំណែង)

<u>មន្ត្រីបច្ចេកទេសព័ត៌មានវិទ្យា (១០) រូប ត្រូវមានគុណវុឌ្ឍិ ដូចខាងក្រោម</u>÷

- មានសញ្ញាប័ត្រទាបបំផុតត្រឹមបរិញ្ញាប័ត្រផ្នែកព័ត៌មានវិទ្យា ឬប្រហាក់ប្រហែល (សម្រាប់តំណែង Web Developer / Programmer, IT Security Analyst/Specialist និង System Administrator)
- ផ្តល់អាទិភាពខ្ពស់ជូនបេក្ខជនដែលមានជំនាញលើកម្មវិធី Android and iOS developing (សម្រាប់តំណែង Web Developer/Programmer)
- មានបទពិសោធន៍ការងារយ៉ាងតិច០១ឆ្នាំ លើតំណែងដែលមានចំណាប់អារម្មណ៍
- ផ្តល់អាទិភាពដល់បេក្ខជនដែលមានបទពិសោធន៍លើផលិតផល Oracle និង Unix

ការជ្រើសរើសនេះ បើកចំហដល់បេក្ខជន ឬបេក្ខនារីទាំងអស់ដើម្បីមកបម្រើការងារពេញម៉ោងនៅអគ្គលេខាធិការដ្ឋាន។ ស្ត្រីត្រូវបានផ្តល់អាទិភាពសម្រាប់មុខតំណែងនីមួយៗ។

ប្រាក់បៀវត្ស/ប្រាក់ឧបត្ថម្ភ នឹងត្រូវទទួលបានសមរម្យទៅតាមមុខតំណែង និងផ្អែកលើសមត្ថភាព បទពិសោធន៍ និង គុណវុឌ្ឍិរបស់បេក្ខជន ឬបេក្ខនារី។

បេក្ខជន ឬបេក្ខនារីដែលមានចំណាប់អារម្មណ៍ សូមមកដាក់ពាក្យសុំចូលបម្រើការងារដោយភ្ជាប់មកជាមួយនូវប្រវត្តិរូបសង្ខេប និង cover letter ព្រមទាំងឯកសារពាក់ព័ន្ធ នៅអាស័យដ្ឋានខាងក្រោមរាល់ម៉ោងធ្វើការយ៉ាងយូរបំផុតត្រឹមថ្ងៃទី០២ ខែសីហា ឆ្នាំ ២០១៧ វេលាម៉ោង៥ និង ៣០នាទី ល្ងាច។ **សូមទាញយកលក្ខខណ្ឌយោងតាមគេហទំព័រ www.pfm.gov.kh**។

ព័ត៌មានបន្ថែម សូមទាក់ទងលោក នួន រតនៈសម្បត្តិ តាមអស័យដ្ឋានដូចខាងក្រោម÷

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
ទីតាំងលេខ ៦០ ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
បន្ទប់អគ្គលេខាធិការដ្ឋានកំណែទម្រង់ អគារ "គ" ជាន់ទី៧
ទូរស័ព្ទទាក់ទង : 089 888 180/ 023 430 791
អ៊ីមែល: nounrathanaksambath@pfm.gov.kh / huy.sovannara@pfm.gov.kh